ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** ជាតិ សាសនា ព្រះមហាក្សត្រ

លេខៈ ១១៣ អនក្រ.បក

# អនុក្រឹត្យ
# ស្ដីពី
# ការបង្កើតក្រុមការងារកំណែទម្រង់រដ្ឋបាលនៅតាមក្រសួង ស្ថាប័ន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៤/២៨៤ ចុះថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០០៤ ស្ដីពីការបង្កើតឧត្ដមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៨/៣៨៦ ចុះថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០០៨ ស្ដីពីគោលការណ៍រួមនៃការបង្កើត និងដាក់ឱ្យដំណើរការទីភ្នាក់ងារប្រតិបត្តិការពិសេស
- បានឃើញអនុក្រឹត្យលេខ ៥១ អនក្រ.បក ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ១៩៩៩ ស្ដីពីការបង្កើតក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០០៩ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ២៩ អនក្រ.បក ចុះថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០០៨ ស្ដីពីការអនុវត្តប្រាក់លាភការបន្ថែមដោយផ្អែកលើលទ្ធផលការងារ

- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០០៩ ស្តីពីការបង្កើត និងដាក់ឱ្យដំណើរការកម្មវិធីកន្សោមអាទិភាព
- បានឃើញអនុក្រឹត្យលេខ ៦៨ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០០៩ ស្តីពីការបង្កើតគណៈកម្មាធិការគ្រប់គ្រងប្រសិទ្ធភាពការងារ និងគណនេយ្យភាព
- តាមសំណើរបស់ប្រធានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល

# សម្រេច

**មាត្រា ១.-**

បង្កើតក្រុមការងារកំណែទម្រង់រដ្ឋបាលនៅតាមក្រសួង ស្ថាប័ន ក្នុងគោលដៅសម្របសម្រួលការអនុវត្តកម្មវិធី យុទ្ធសាស្ត្រ និងសកម្មភាពកំណែទម្រង់រដ្ឋបាលនៅក្នុងក្រសួង ស្ថាប័នសាមី តាមការចង្អុលទិសរបស់ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ។

**មាត្រា ២.-**

ក្រុមការងារកំណែទម្រង់រដ្ឋបាលនៅតាមក្រសួង ស្ថាប័ន ត្រូវស្ថិតនៅក្រោមការដឹកនាំ និងគ្រប់គ្រងរបស់រដ្ឋមន្ត្រី ឬប្រធានស្ថាប័នសាមី ។

ក្រុមការងារកំណែទម្រង់រដ្ឋបាលនៅតាមក្រសួង ស្ថាប័នមានសមាសភាពដូចខាងក្រោម:

| | |
|---|---|
| - រដ្ឋលេខាធិការ ឬអនុរដ្ឋលេខាធិការ ឬឋានៈស្មើក្នុងរចនាសម្ព័ន្ធ | ០១ រូប ជាប្រធាន |
| - អគ្គនាយក/អគ្គនាយករង ឬអគ្គលេខាធិការ/អគ្គលេខាធិការរង ឬ អគ្គាធិការ/អគ្គាធិការរង ឬឋានៈស្មើក្នុងរចនាសម្ព័ន្ធ | ០១ រូប ជាសមាជិក |
| - ប្រធាន/អនុប្រធាននាយកដ្ឋានជំនាញ ឬឋានៈស្មើក្នុងរចនាសម្ព័ន្ធ | ០១ រូប ជាសមាជិក |
| - មន្ត្រីជំនាញ | ០២ រូប ជាជំនួយការ |

**មាត្រា ៣.-**

ក្រុមការងារកំណែទម្រង់រដ្ឋបាលនៅតាមក្រសួង ស្ថាប័ន មានតួនាទី និងភារកិច្ចចម្បងៗដូចខាងក្រោម:

- ទទួលខុសត្រូវចំពោះមុខរដ្ឋមន្ត្រី ឬប្រធានស្ថាប័នសាមីក្នុងការគ្រប់គ្រងនិងដឹកនាំគ្រប់ការងារពាក់ព័ន្ធទៅនឹងកម្មវិធី យុទ្ធសាស្ត្រ និងសកម្មភាពកំណែទម្រង់រដ្ឋបាលរបស់ក្រសួង ស្ថាប័ន
- សម្របសម្រួលការងារកំណែទម្រង់រដ្ឋបាល រវាងក្រសួង ស្ថាប័នសាមី ជាមួយអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល និងកំណែទម្រង់តាមវិស័យ
- សម្របសម្រួល និងជំរុញការអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ និងសកម្មភាពកំណែទម្រង់រដ្ឋបាល
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ព្រមទាំងធ្វើរបាយការណ៍ស្តីពីវឌ្ឍនភាពនៃការអនុវត្តកម្មវិធីកំណែទម្រង់រដ្ឋបាលជូនរដ្ឋមន្ត្រី ឬប្រធានស្ថាប័ននិងក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល

**មាត្រា ៤.-**

ក្រុមការងារកំណែទម្រង់រដ្ឋបាលនៅតាមក្រសួង ស្ថាប័នត្រូវដើរតួនាទីជាក្រុមការងារគ្រប់គ្រងប្រសិទ្ធភាពការងារ និងគណនេយ្យភាព និងមានភារកិច្ចក្នុងការសម្របសម្រួលការរៀបចំសំណើ ការបង្កើត ការដាក់ឱ្យដំណើរ-

ការ ការគ្រប់គ្រង និងការតាមដាន ត្រួតពិនិត្យ ការអនុវត្តកម្មវិធីកន្សោមអាទិភាព ប្រាក់លាភការបន្ថែមដោយផ្អែកលើលទ្ធផលការងារ និងទីភ្នាក់ងារប្រតិបត្តិការពិសេស ។

**មាត្រា ៥.–**

ប្រធានក្រុមការងារកំណែទម្រង់រដ្ឋបាលនៅតាមក្រសួង ស្ថាប័នត្រូវដើរតួនាទីជាអនុប្រធាន ឬសមាជិកនៃគណៈកម្មាធិការគ្រប់គ្រងប្រសិទ្ធភាពការងារ និងគណនេយ្យភាព ។

សមាជិកក្រុមការងារកំណែទម្រង់រដ្ឋបាលនៅតាមក្រសួង ស្ថាប័នដែលជាអគ្គនាយក/ អគ្គនាយករង ឬអគ្គលេខាធិការ / អគ្គលេខាធិការរង ឬអគ្គាធិការ/អគ្គាធិការរង ឬឋានៈស្មើក្នុងរចនាសម្ព័ន្ធត្រូវដើរតួនាទីជានាយកកម្មវិធីកន្សោមអាទិភាព ។

ក្រុមការងារកំណែទម្រង់រដ្ឋបាលនៅតាមក្រសួង ស្ថាប័នអាចដើរតួនាទីនៅក្នុងផ្នែកផ្សេងៗទៀតតាមការចាត់តាំងរបស់រដ្ឋមន្ត្រី ឬប្រធានស្ថាប័នទាក់ទងទៅនឹងវិស័យកំណែទម្រង់រដ្ឋបាល ។

**មាត្រា ៦.–**

ការតែងតាំងសមាសភាពក្រុមការងារកំណែទម្រង់រដ្ឋបាលនៅតាមក្រសួង ស្ថាប័នត្រូវធ្វើឡើងដោយសេចក្តីសម្រេចរបស់ប្រធានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល តាមសំណើរបស់រដ្ឋមន្ត្រីក្រសួង ឬប្រធានស្ថាប័នសាមី ។

**មាត្រា ៧.–**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៨.–**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៩

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**

នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា សូមមេត្តាចុះហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**និងជាប្រធានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល**

**សុខ អាន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៨
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ